១៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

338
31-3-2016

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ៩០៦៦
ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២
សាលក្រមព្រហ្មទណ្ឌ
លេខ ០១គប.១ "ឃ"
ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង៨៖៣០ នាទី ព្រឹក ដែលមានសមាសភាពជំនុំជម្រះដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើជនជាប់ចោទដូចខាងក្រោម៖

១-ឈ្មោះ [redacted] ផង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិរបុញ ឃុំត្រពាំងប្រសាទ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្ន [redacted] ប្រសាទ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០២នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ជានីតិជន។

-ឃុំខ្លួនតាមដីកាលេខ២២៧២ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិរបុញ ឃុំត្រពាំងប្រសាទ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្នភូមិរបុញ ឃុំ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

-ឃុំខ្លួនតាមដីកាលេខ២២៧១ ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

៣-ឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ សញ្ជាតិឡាវ ទីកន្លែងកំណើតស្រុកប៉ាគីម នគរហ្លួង-វៀងចន្ទ ប្រទេសឡាវ មានទីលំនៅបច្ចុប្បន្នស្រុកប៉ាគីម នគរហ្លួង-វៀងចន្ទ ប្រទេស

Scanned with CamScanner

ឡាវ ប្រពន្ធឈ្មោះ ប៉ុង (រ) មានកូន០២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) ទោសពីមុនគ្មាន ជានីតិជន។

-ឃុំខ្លួនតាមដីកាលេខ២២៧៣ ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

៤-ឈ្មោះ [redacted]ាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជន់ជាតិឡាវ សញ្ជាតិឡាវ ទីកន្លែងកំណើត ស្រុកប៉ាកថង ខេត្តចំប៉ាសាក់ ប្រទេសឡាវ មានទីលំនៅបច្ចុប្បន្នស្រុកសុខុមម៉ា ខេត្តចំប៉ាសាក់ ប្រទេសឡាវ ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០៥នាក់ ឪពុកឈ្មោ[redacted](រ) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន ជានីតិជន។

-ឃុំខ្លួនតាមដីកាលេខ២២៧០ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

ជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារបូលីណាផាឡេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២។

-បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង១៤$^{h}$ ១៥នាទី ដោយអនុវត្តវិធានបញ្ជូនញ៉ង់ឲ្យលក់ខុសច្បាប់នូវសារធាតុញៀន កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន និងដោយមានការដឹកនាំសម្របសម្រួលដោយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចសណ្ឋាគារបូលីណាផាលេស បន្ទាប់លេខ៥០៣ ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ផង និងឈ្មោះ [redacted] សុត ពេលកំពុងធ្វើសកម្មភាពប្រព្រឹត្តបទល្មើសជាក់ស្តែង យកថ្នាំប្រភេទគ្រាប់ផ្ការឈូកសង្ស័យថា ជាគ្រឿងញៀនលាក់ទុកក្នុងការបូបទៅប្រគល់ឲ្យម៉ូយក្រោមការបញ្ជារពីឈ្មោះ សម្រស់ និងឈ្មោះ ផល្លី ព្រមទាំងដកហូតបានវត្ថុតាងប្រភេទថ្នាំគ្រាប់ពណ៌ផ្ការឈូកសង្ស័យថាគ្រឿងញៀនទម្ងន់១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) និងសម្ភារៈចាប់យករួមមានទូរស័ព្ទដៃម៉ាក S-wellcom មួយគ្រឿង។

លុះដល់វេលាម៉ោង១៤$^{h}$២៥នាទី នាថ្ងៃខែឆ្នាំដដែល កម្លាំងចម្រុះបានបន្តធ្វើការឆែកឆេបន្ទប់លេខ១៣ ក្នុងផ្ទះសំណាក់ផ្កាមាស សង្កាត់ព្រែកលៀប ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ផន គុម្ភភន់ និងឈ្មោះ [redacted] ខាំបៃ ដែលជាអ្នកជួញដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] ខាំ ជាជនជាតិភូមា និងឈ្មោះ ផល្លី ព្រមទាំងឈ្មោះ សម្រស់ តាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] ផង និងបានចាប់យកសម្ភារៈរួមមានរថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, ទូរស័ព្ទដៃម៉ាកNOKIA ចំនួនមួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង, លិខិតឆ្លងដែនចំនួនពីរច្បាប់, កូនសៀវភៅ

ចំនួនពីរក្បាល, បណ្ណធនាគារចំនួនពីរច្បាប់ និងអត្តសញ្ញាណបណ្ណចំនួនមួយច្បាប់ ដើម្បីកសាងសំណុំរឿង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមច្បាប់។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៩១៨អ.យ.ត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៦៨៥ដ.ដ.រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចយកជនជាប់ចោទមកជំនុំជម្រះលេខ៦៣តព្រ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] គុមភន់ បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយអះអាងថា ខ្លួនបានមកភ្នំពេញពិតមែន តែខ្លួនមកដើម្បីជូនឈ្មោះ[redacted] ខាំបៃ ទិញគ្រឿងអគ្គិសនី, ទិញថ្នាំពេទ្យ និងមកដើរកំសាន្តផង មិនមែនមកជួញដូរគ្រឿងញៀនដូចការចោទប្រកាន់នោះទេ។ ខ្លួនបានមកភ្នំពេញចំនួនពីរលើក ដោយលើកទីមួយនៅថ្ងៃទី២២ ហើយបានត្រលប់ទៅវិញ ដោយសំបុត្រឡានផុតកាលបរិច្ឆេទកំណត់ លុះថ្ងៃទី២៣ បានមកម្តងទៀតជាមួយឈ្មោះ[redacted] ខាំបៃ ឈ្មោះ ផល្លី និងរូបគាត់។ ពេលសមត្ថកិច្ចឃាត់ខ្លួន [redacted] គុមភន់) និងឈ្មោះ[redacted] ខាំបៃ គឺនៅផ្ទះសំណាក់ ចំណែកឈ្មោះ ផល្លី មិនបានឃាត់ទេ ព្រោះឈ្មោះនេះនៅដេកបន្ទប់ផ្សេង ហើយពេលឃាត់ខ្លួននោះ សមត្ថកិច្ចមិនបានឆែកចាប់បានគ្រឿងញៀននោះទេ ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] ផង [redacted] ស៊ុត ទេ ដោយក៏មិនដឹងថា អ្នកទាំងពីរម្នាក់គ្រឿងញៀនដែរ ។ ខ្លួនសុំបដិសេធចម្លើយដែលខ្លួនបានឆ្លើយនៅប៉ូលីស ចោលព្រះខ្លួនស្តាប់អ្នកបកប្រែមិនសូវយល់ ហើយមានការភិតភ័យពេក ចេះតែផ្តិតមេដៃទៅ គឺខ្ញុំសុំបដិសេធត្រង់ពីរចំណុច ចំណុចទីមួយដែលថា ខ្លួនបានទៅជួបស្រីម្នាក់អាយុប្រហែល៤០ឆ្នាំ ដើម្បីពិនិត្យលុយ និងចំណុចទី២ ដែលថាខ្លួនមកភ្នំពេញដើម្បីជួញដូរគ្រឿងញៀនចោល។

-ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទ ព្រោះខ្លួនមកជាមួយឈ្មោះ[redacted] គុមភន់ ដើម្បីទិញគ្រឿងអគ្គិសនី ទិញថ្នាំព្យាបាលសន្លាក់ និងជម្ងឺថ្លើម។ ខ្លួនបានមកភ្នំពេញចំនួនពីរលើក លើកទីមួយមានគ្នាប្រាំមួយនាក់ ដោយស្គាល់តែឈ្មោះ ផល្លី ឈ្មោះ គុមភន់ អ្នកផ្សេងទៀតមិនស្គាល់ទេ ការមកលើកទីមួយនេះ មិនទាន់បានបានទិញគ្រឿងអគ្គិសនី និងថ្នាំពេទ្យទេ ដោយសារលិខិតអនុញ្ញាតិឡានរបស់ឈ្មោះ [redacted] គុមភន់ ជិតផុតកំណត់។ ចំពោះការមកលើកទី២ ក្នុងគោលបំណងដដែល មិនបែនមកជួញដូរគ្រឿងញៀនទេ ខ្លួនសុំបដិសេធចម្លើយដែលបានចម្លើយនៅចំពោះមុខសមត្ថកិច្ច ព្រោះខ្លួនស្តាប់អ្នកបកប្រែមិនសូវយល់ ចេះតែយល់ព្រមផ្តិតមេដៃទៅ។ ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ បានបញ្ជាក់បន្ថែមទៀតថា ខ្លួនស្គាល់ឈ្មោះ[redacted] ផង ច្បាស់ ព្រោះធ្លាប់ទំនាក់ទំនងទិញសត្វព្រៃជាមួយគ្នា ចំណែកឈ្មោះ ផល្លី ខ្លួនស្គាល់តាមរយៈឈ្មោះ[redacted] ផង ខ្លួនស្គាល់មិនសូវច្បាស់ទេ ហើយក៏មិនស្គាល់ឈ្មោះ ផល្លី ដែរ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនគ្មានគ្រឿងញៀនទេ។

-ជនជាប់ចោទឈ្មោះ[redacted] ផង បានឆ្លើយបដិសេធថា ខ្លួនបានមកភ្នំពេញចំនួនពីរលើក លើកទីមួយ ដើម្បីជូនឈ្មោះ [redacted] ខាំបៃ ទិញថ្នាំពេទ្យ និងម៉ាស៊ីនភ្លើង មានគ្នាប្រាំមួយនាក់ ដោយដេកផ្ទះសំណាក់ជាមួយគ្នា នៅថ្ងៃនោះ ខ្លួនឃើញមានគេមកទំនាក់ទំនងជាមួយឈ្មោះ សម្រស់ និងឈ្មោះ ផល្លី ។ លើកទីមួយនេះមិនបានទិញថ្នាំពេទ្យ

និងម៉ាស៊ីនភ្លើងទេ ដោយសំបុត្រឡានផុតកំណត់ក៏ត្រលប់ទៅវិញ ។ លើកទីពីរមកភ្នំពេញជាមួយឈ្មោះ សម្រស់ ជិះឡានតាក់ស៊ី ដោយឈ្មោះ សម្រស់ ប្រាប់ថាឲ្យខ្ញុំមកភ្នំពេញ ដើម្បីធ្វើកម្មករសាងសង់ផ្ទះរបស់បងថ្លៃគាត់ ពេលមកដល់ភ្នំពេញ ឈ្មោះ សម្រស់ បាននាំខ្លួនទៅដេកនៅផ្ទះរបស់បងស្រីគេ ពេលចូលដល់បន្ទប់ដេក ឈ្មោះ សម្រស់បានទុកកាបូបរបស់ខ្លួននៅលើគ្រែរួចចេញទៅក្រៅដោយប្រាប់ខ្លួនថា ចេញទៅយកឥវ៉ាន់ឲ្យម៉ាក់គេ ពេលឈ្មោះ សម្រស់ ចេញផុត ស្រាប់តែប៉ូលីសចូលមកចាប់ខ្លួនតែម្តង ដោយខ្លួនមិនដឹងថា កាបូបរបស់ឈ្មោះសម្រស់មានគ្រឿងញៀនទេ។ មុននឹងចេញមកភ្នំពេញឈ្មោះ សម្រស់ បានសន្យាឲ្យអង្គុយខ្លួនពីរបេ តែមិនបាននិយាយថា ឲ្យលុយចំនួនមួយរយដុល្លារទេ។ ចំពោះឈ្មោះ [redacted] ស៊ុត ខ្លួនមិនដែលស្គាល់នោះទេ។

-ជនជាប់ចោទឈ្មោះ ណាក ស៊ុត បានឆ្លើយបដិសេធនាពេលសវនាការថា ខ្លួនមិនបានដឹងរឿងអ្វីទេ ពេលខ្លួនមកទិញបាយហូបស្រាប់តែប៉ូលីសចាប់ខ្លួនតែម្តង ចំពោះឆ្លើយដែលខ្លួនបានឆ្លើយនៅប៉ូលីសខ្លួនមិនដឹងទេ ប៉ូលីសចេះតែឲ្យផ្តិតមេដៃ ហើយពេលដែលសមត្ថកិច្ចឃាត់ខ្លួននៅផ្ទះសំណាក់ ខ្លួនគ្មានគ្រឿងញៀនទេ ហើយខ្លួនក៏មិនដែលស្គាល់ឈ្មោះ [redacted] ផង ឈ្មោះ ផល្លី ឈ្មោះ សម្រស់ និងជនជាតិឡាវទាំងពីរនាក់នេះដែរ។

-លោកអនុសេនីយឯក[redacted] ឋាន:នាយផ្នែក នៃមន្ទីរប្រឆាំងគ្រឿងញៀន បានបញ្ជាក់នាពេលសវនាការថា បន្ទាប់ពីមានការអនុញ្ញាតិពីលោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ដោយអនុវត្តតាមវិធានញុះញ៉ង់ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ភ្នាក់ងារកម្លាំងសម្ងាត់ បានធ្វើការណាត់ជួបជាមួយឈ្មោះ [redacted] ផង , [redacted] ខាំបៃ, [redacted] គុមភន់, ផល្លី, សម្រស់ នៅផ្ទះសំណាក់សារិកា ដើម្បីពិភាក្សាគ្នារឿងជួញដូរគ្រឿងញៀន និងពិនិត្យលុយ បន្ទាប់ពីការណាត់ជួបភាគីខាងលើ បានត្រលប់ទៅខេត្តវិញ។ លុះដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ ភ្នាក់ងារសម្ងាត់បានណាត់ជួបភាគីខាងលើដើម្បីប្រគល់ទំនិញ នៅផ្ទះសំណាក់តារា ដោយជួបជាមួយជនជាតិឡាវទាំងពីរនាក់។ ជនជាតិឡាវទាំងពីរនាក់នេះបានឲ្យលេខទូរស័ព្ទរបស់ឈ្មោះ ផល្លី, [redacted] ផង និងឈ្មោះ[redacted]ស៊ុត ដោយបញ្ជាក់ថា ថ្នាំញៀននៅអ្នកទាំងបីនាក់។ ឈ្មោះ [redacted] ផង,[redacted]ស៊ុត និងឈ្មោះ ផល្លី បានមកភ្នំពេញជាមួយគ្នាហើយថ្នាំញៀន ក្រុមប្រតិបត្តិការចាប់បាននៅបន្ទប់របស់ឈ្មោះ [redacted] ផង ប៉ុន្តែគ្រឿងញៀននេះមិនមែនជារបស់ឈ្មោះ [redacted] ផង ទេ គឺរបស់ឈ្មោះ[redacted] ខាំបៃ និងឈ្មោះ[redacted] គុមភន់។ ឈ្មោះ សម្រស់ និងឈ្មោះ ផល្លី មិនមែនជាកម្លាំងសម្ងាត់ទេ គឺជាមុខសញ្ញាមេក្លោងជួញដូរគ្រឿងញៀន ពេលសមត្ថកិច្ចចុះបង្ក្រាប សមត្ថកិច្ចចាប់ខ្លួនអ្នកទាំងពីរទេ។ ចំពោះការទំនាក់ទំនងរវាងជនជាតិឡាវ និងកម្លាំងសម្ងាត់ មានឈ្មោះ សម្រស់ ជាអ្នកបកប្រែ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាង។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-តំណាងអយ្យការសន្និដ្ឋាន៖ ឆ្លងតាមការពិភាក្សាដេញដោលឃើញថា កម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន ចុះបង្ក្រាបការជួញដូរគ្រឿងញៀននៅសណ្ឋាគារបូលីណាផាឡាស ដោយអនុវត្តតាមវិធានញុះញ៉ង់ ដោយឃាត់ខ្លួនឈ្មោះ[redacted]ផង, [redacted]ុត និងគ្រឿងញៀន រួចបន្តទៅឃាត់ខ្លួនឈ្មោះ [redacted]ខាំបៃ និងឈ្មោះ [redacted] គុមភន់ទៀត ។ ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាល ប៉ុន្តែនាពេលសវនាការស្រាប់តែបដិសេធថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទៅវិញ។ ការឆ្លើយបដិសេធនេះគ្មានភស្តុតាងស៊ីសង្វាក់ គ្មានតម្លៃជាភស្តុតាង ដែលអាចជឿបាននោះទេ ម្យ៉ាងទៀតមានភស្តុតាងយ៉ាងច្បាស់បញ្ជាក់ថា ក្រុមជនជាប់ចោទបានសហការគ្នាយ៉ាងស្អិតរមួតក្នុងការប្រព្រឹត្តការជួញដូរគ្រឿងញៀន រហូតដល់មានការបង្ក្រាបជាក់ស្តែង។ ដោយផ្អែកតាមលទ្ធផលកោសលវិច័យរបស់

អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន បញ្ជាក់យ៉ាងច្បាស់ថា វត្ថុចាប់យក ជាសារធាតុញៀន ដែលច្បាប់បានហាមឃាត់ ដូច្នេះស្នើសុំតម្កល់បទចោទដូចដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-លោក [redacted] វិសាល ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនបានឆ្លើយបដិសេធគ្រប់ដំណាក់កាលថា ខ្លួនពុំមានគ្រឿងញៀនទេ ជាក់ស្ដែងសមត្ថកិច្ចក៍មិនមែនចាប់គ្រឿងញៀនពីកូនក្ដីខ្លួនដែរ ថ្នាំញៀនគឺស្ថិតនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ផង, [redacted] ស៊ុត អ្នកទាំងពីរនេះ កូនក្ដីខ្លួនមិនស្គាល់ទេ។ ចំពោះការដែលកូនក្ដីខ្លួនមកភ្នំពេញ កូនក្ដីខ្លួនបានធ្វើលិខិតអនុញ្ញាតត្រឹមត្រូវ ហើយមានគោលបំណងច្បាស់លាស់ ដើម្បីទិញគ្រឿងអគ្គីសនី , ទិញថ្នាំពេទ្យ និងមកកំសាន្តនៅភ្នំពេញ មិនមែនមកដើម្បីជួញដូរគ្រឿងញៀន ដូចការចោទប្រកាន់នោះទេ ឈ្មោះ ផល្លី ឈ្មោះ សម្រស់ ទើបជាមេឃ្លោងពិតប្រាកដ។ ការចោទប្រកាន់កូនក្ដីខ្លួន នៅពុំមានមានអង្គហេតុច្បាស់លាស់ ពោលគឺនៅមានវិមតិសង្ស័យនៅឡើយ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យ ត្រូវមានប្រយោជន៍ដល់ជនជាប់ចោទ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីតំណាងដោយអាណត្តិ សុំស្នើឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទលើកូនក្ដីខ្ញុំផង។

-លោក [redacted] ទ្ធី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ បានធ្វើសេចក្ដីសន្និដ្ឋានថា អង្គហេតុបានបញ្ជាក់យ៉ាងច្បាស់ថា នៅពុំទាន់មានអំពើ ជួញដូរគ្រឿងញៀនបានកើតឡើងនៅឡើយ ពោលគឺគ្រឿងញៀនត្រូវបានយកមកទុកលើគ្រែបន្ទប់របស់ឈ្មោះ [redacted] ផង ដែលជាគ្រឿងញៀនរបស់ឈ្មោះ សម្រស់ គឺពុំទាន់មានការដោះដូររវាងអ្នកទិញ និងអ្នកលក់នៅឡើយ ពោលគឺធាតុសត្យានុម័តមិនទាន់ស្ដែងឡើងនៅឡើយ ដូច្នេះមិនអាចអនុវត្តតាមមាត្រា៤០ ផ្ដន្ទាទោសលើជនជាប់ចោទបានឡើយ។ មាត្រា៣៥៧ បញ្ជាក់ថា អង្គហេតុដែលសរសេរនៅក្នុងសាលក្រមត្រូវតែច្បាស់លាស់ ប៉ុន្តែអង្គហេតុខាងលើនេះនៅមានវិមតិសង្ស័យនៅឡើយ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទលើកូនក្ដីខ្ញុំបាទ និងស្នើសុំឱ្យតុលាការសម្រេចប្រគល់រថយន្តឱ្យម្ចាស់ដើមវិញផង។

-លោក [redacted] ហ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនពុំមានតួនាទីជាអ្នកដឹកជញ្ជូនរឿងញៀនទេ ដោយហេតុសារកូនក្ដីខ្លួនពុំបានដឹងជាមុនថា នៅក្នុងការប្លុបមានគ្រឿងញៀន ហើយការប្លុបនោះជារបស់ឈ្មោះ សម្រស់ មិនមែនជារបស់កូនក្ដីខ្លួនទេ កូនក្ដីខ្លួនមិនមែនជាកាន់ឃ្លុការប្លុបនោះឡើយ ថ្នាំញៀននោះគឺនៅលើគ្រែ។ កូនក្ដីខ្លួនមកភ្នំពេញជាមួយឈ្មោះ សម្រស់ ព្រោះឈ្មោះ សម្រស់ ប្រាប់ថា ឱ្យខ្លួនមកធ្វើការជាជាងសំណង់ សាងសង់ផ្ទះបងថ្លៃរបសគេ ដោយសន្យាឱ្យអង្គពីររបេ អង្គហេតុខាងលើនេះមិនមានធាតុផ្សំគ្រប់គ្រាន់ពីបទ ជួញដូរគ្រឿងញៀននោះទេ ម្យ៉ាងវិញទៀតកូនក្ដីខ្លួនពុំសូវមានការយល់ដឹង ដូច្នេះស្នើសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទ។

-សំដីចុងក្រោយរបស់ជនជាប់ចោទទាំងបួនរូប៖ ស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ និងស្នើសុំឱ្យតុលាការដោះលែងពួកខ្លួនវិញ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ។

-ក្រោយពីស្ដាប់ចម្លើយសាក្សី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ។



Scanned with CamScanner

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

**យល់ឃើញថា:**

-ពិតជាកើតមាននូវអំពើល្មើសបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ៥០៣ សណ្ឋាគារ បូលីណា ផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ ដែលបង្កឡើងដោយឈ្មោះ[redacted] ថង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, [redacted] ស៊ិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ, [redacted] គុបភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ , [redacted] ខាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ ប្រាកដមែន។

-អំពើ និងសកម្មភាពប្រព្រឹត្តល្មើសរបស់ជនជាប់ចោទឈ្មោះ[redacted] ថង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ,[redacted] ស៊ិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ, [redacted] គុបភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ ,[redacted] ខាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ ស្ថិតនៅទីកន្លែង និងពេលវេលាខាងលើ មានធាតុផ្សំគ្រប់គ្រាន់ជាបទៈជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ជនជាប់ចោទឈ្មោះ[redacted]ថង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, [redacted] ស៊ិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ,[redacted] គុបភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ, [redacted] ខាំបៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ មានស្មារតីជាទាល្អ ជានីតិជន ជាសមត្ថជន មានសមត្ថភាពគ្រប់គ្រាន់ទទួលខុសត្រូវនូវទោសព្រហ្មទណ្ឌផ្ទាល់ខ្លួន ទោះបីខ្លួនដឹងថា អំពើនេះនឹងកើតមានព្យសនកម្មប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមក៏ដោយខ្លួននៅតែប្រព្រឹត្ត។ ជាក់ស្តែងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង១៤ʰ ១៥នាទី ដោយអនុវត្តវិធានញុះញង់ឲ្យលក់ខុសច្បាប់នូវសារធាតុញៀន កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន និងដោយមានការដឹកនាំសម្របសម្រួលដោយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចសណ្ឋាគារ បូលីណាផាលេស បន្ទាប់លេខ៥០៣ ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ថង និងឈ្មោះ[redacted] ស្មុត ពេលកំពុងធ្វើសកម្មភាពប្រព្រឹត្តបទល្មើសជាក់ស្តែង យកថ្នាំប្រភេទគ្រាប់ផ្ការឈូកសង្ស័យថា ជាគ្រឿងញៀនលាក់ទុកក្នុងការបូប ទៅប្រគល់ឲ្យមួយ ក្រោមការបញ្ជារពីឈ្មោះសម្រស់ និងឈ្មោះ ផល្លី ព្រមទាំងដកហូតបានវត្ថុតាងប្រភេទថ្នាំគ្រាប់ពណ៌ផ្ការឈូកសង្ស័យថា គ្រឿងញៀនទម្ងន់១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) និងសម្ភារៈចាប់យករួមមានទូរស័ព្ទដៃម៉ាក S-wellcom មួយគ្រឿង។ លុះដល់វេលាម៉ោង១៤ʰ ២៥នាទី នាថ្ងៃខែឆ្នាំដដែល កម្លាំងចម្រុះបានបន្តធ្វើការឆែកឆេរបន្ទប់លេខ១៣ ក្នុងផ្ទះសំណាក់ផ្កាមេឃ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] គុមភន់ និងឈ្មោះ[redacted] ខាំបៃ ដែលជាអ្នកជួញដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] ខាំ ជាជនជាតិភូមា និងឈ្មោះ ផល្លី ព្រមទាំងឈ្មោះ សម្រស់



Scanned with CamScanner

តាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] ផង និងបានចាប់យកសម្ភារៈរួមមានរថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, ទូរស័ព្ទដៃម៉ាកNOKIA ចំនួនមួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង, លិខិតឆ្លងដែនចំនួនពីរច្បាប់, កូនសៀវភៅចំនួនពីរក្បាល, បណ្ណធនាគារចំនួនពីរច្បាប់ និងអត្តសញ្ញាណបណ្ណចំនួនមួយច្បាប់ ដើម្បីកសាងសំណុំរឿង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមច្បាប់។ អំពើនឹងសកម្មភាពរបស់ជនជាប់ចោទឈ្មោ [redacted] ផង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, [redacted] ស៊ិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ, [redacted] គុបភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ, [redacted] ខាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ ដូចខាងលើ គឺជាការប្រព្រឹត្តដោយចេតនានូវបទល្មើសព្រហ្មទណ្ឌជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ផង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ, [redacted] ស៊ិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ, [redacted] គុបភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ , [redacted] ខាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារ បូលីណា ផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

<u>ភស្តុតាងមាន៖</u>

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផង បានឆ្លើយនៅសមត្ថកិច្ច នៅអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ ឈ្មោះ សម្រស់ បានមកពីកពាក់ខ្លួន និងបងប្រុសខ្លួនឈ្មោះ [redacted] ស៊ិត ឲ្យជួយជូនគាត់មកភ្នំពេញ ដោយគាត់សន្យាឲ្យប្រាក់ចំនួន១០០$ (មួយរយដុល្លារអាមេរិក) និងអង្គពីរបេ នៅពេលត្រលប់មកវិញ។ នៅពេលមកដល់ភ្នំពេញឈ្មោះ សម្រស់ បានពឹងឲ្យខ្លួនយូកាបូបឲ្យគាត់ ហើយគាត់បាននាំពួកខ្លួនទៅដេកនៅសណ្ឋាគារបូលីណា នៅបន្ទប់លេខ៥០៣ ។ នៅពេលមកដល់សណ្ឋាគារបូលីណា ប្រហែល២០នាទី ឈ្មោះ សម្រស់ប្រាប់ខ្លួនថា គាត់យកឥវ៉ាន់ទៅឲ្យម៉ៃគាត់មួយភ្លែត។ ភ្លាមនោះស្រាប់តែមានសមត្ថកិច្ចចូលមកឆែកឆេរបន្ទប់ដែលខ្លួនស្នាក់នៅ ហើយសមត្ថកិច្ចបានឆែកឆេក្នុងកាបូបរបស់ឈ្មោះ សម្រស់ ឃើញមានថ្នាំញៀនទម្ងន់ ១៨៣៨,៤ក្រាម។ នៅពេលនោះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងបងប្រុសខ្លួនឈ្មោះ [redacted] ស៊ិត តែម្តង។

-តាមចម្លើយរបស់ឈ្មោះ [redacted] ស៊ិត បានឆ្លើយនៅសមត្ថកិច្ច នៅអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង១៤ និ១៥នាទី នៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារបូលីណា ផាឡេស រាជធានីភ្នំពេញ ពេលដែលសមត្ថកិច្ចរកឃើញថ្នាំញៀនក្នុងបន្ទប់ជួលរបស់ខ្លួន។ ថ្នាំញៀនដែលសមត្ថកិច្ចធ្វើការដកហូតនេះពិតជារបស់ឈ្មោះ សម្រស់ ដែលបានឲ្យខ្លួន និងបងប្រុសឈ្មោះ [redacted] ផង ជួនយកមកប្រគល់ឲ្យម៉ូយរបស់គាត់ពិតប្រាកដមែន។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង៥ និង ០០ នាទី ខ្លួន និងបងប្រុសឈ្មោះ [redacted] ផង ពិតជាបានជួបឈ្មោះ សម្រស់ យកថ្នាំញៀនមកភ្នំពេញ ដើម្បីប្រគល់ឲ្យម៉ូយ ដោយឈ្មោះ សម្រស់ សន្យាប្រគល់ប្រាក់១០០$ ពេលខ្លួនជូនគាត់មកដល់ភ្នំពេញ។



Scanned with CamScanner

-តាមចម្លើយរបស់ឈ្មោះ [redacted] គុមភន់ បានឆ្លើយនៅសមត្ថកិច្ចថា បានជាសមត្ថកិច្ចឃាត់ខ្លួន ព្រោះខ្លួនបានរកស៊ីជួញដូរគ្រឿងញៀនខុសច្បាប់ លុះមកដល់ អយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា ខ្លួនបដិសេធត្រង់ចំណុចត្រង់ថា ខ្លួនចូលមកស្រុកខ្មែរ ដើម្បីរកស៊ីជួញដូរគ្រឿងញៀន ការពិតខ្លួនចូលមកស្រុកខ្មែរដើម្បីរកទិញគ្រឿងអគ្គីសនី និងថ្នាំព្យាបាលជម្ងឺសន្លាក់។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ខ្លួន និងមិត្តភក្តិបានមកដល់ភ្នំពេញ ហើយបានស្នាក់នៅផ្ទះសំណាក់សារិកានៅម្តុំព្រែកលៀប។ ក្នុងពេលស្នាក់នៅផ្ទះសំណាក់ខាងលើឈ្មោះ ផល្លី និងឈ្មោះ ថង បាននាំខ្លួនទៅជួបស្ត្រីម្នាក់ អាយុប្រហែល៤០ឆ្នាំ នៅក្នុងបន្ទប់មួយផ្សេងទៀត នៅក្នុងផ្ទះសំណាក់នោះដែរ ដោយស្ត្រីនោះបានដកលុយដុល្លារមួយដុំឲ្យឈ្មោះ ថង ហើយឈ្មោះ ថង បានហុចមកឲ្យខ្លួនមើល ហើយខ្លួនមើលដឹងថា លុយនោះពិតប្រាកដមែន រួចខ្លួនទៅបន្ទប់ដេកជាមួយឈ្មោះ ផេន និងឈ្មោះ ខាំបៃ វិញ ។ លុះស្អែកឡើងត្រូវត្រលប់ទៅឡាវវិញ ។ លុះដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោងប្រហែល១១ថ្ងៃត្រង់ខ្លួន ឈ្មោះ ផល្លី ព្រមទាំងឈ្មោះ ខាំបៃ បានត្រលប់មកដល់ភ្នំពេញវិញ ដោយដោយពួកខ្លួនទៅដេកផ្ទះសំណាក់ សមត្ថកិច្ចឃាត់ខ្លួន និងឈ្មោះ ខាំបៃ តែម្តង ឯឈ្មោះ ផល្លី ពុំបានឃាត់ខ្លួនទេ ព្រោះនៅបន្ទប់ផ្សេង។ ក្នុងពេលឃាត់ខ្លួនសមត្ថកិច្ចពុំបានចាប់បានវត្ថុតាងដែលជាគ្រឿងញៀនពីខ្លួន និងឈ្មោះ ខាំបៃ ទេ។

តាមចម្លើយឈ្មោះ [redacted] ខាំបៃ បានឆ្លើយនៅសមត្ថកិច្ច នៅអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ ខ្លួនបានចូលស្រុកខ្មែរជាមួយឈ្មោះ គុមភន់ និងឈ្មោះ ផល្លី ប្រាកដមែន។ ខ្លួនមកដល់ភ្នំពេញនៅម៉ោងប្រហែល១១ជាង ហើយខ្លួនបានទៅដេកនៅផ្ទះសំណាក់ផ្កាយមាស ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ដោយចោទប្រកាន់ថា ពាក់ព័ន្ធរឿងជួញដូរគ្រឿងញៀន។ ពេលសមត្ថកិច្ចឃាត់ខ្លួន ពុំបានរកឃើញគ្រឿញញៀនពីខ្លួនគេទេ។

-របាយការណ៍សំយោគលេខ៤៨៩ រ.ប.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការនគរបាលជាតិ បញ្ជាក់ថា: ឈ្មោះ [redacted] ថង, [redacted] ស៊ុត, [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ... ពិតជាបានប្រព្រឹត្តជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារ បូលីណា ផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។

-កំណត់ហេតុទទួលស្គាល់សម្ភារៈ វត្ថុតាង ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ របស់ការិយាល័យអន្តរាគមន៍មន្ទីរប្រឆាំងគ្រឿងញៀន។

-របាយការណ៍លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ២៤៣០/១៣ អ.ព.អ.ជប.គ.ញ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាកជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ មេតាំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ១៤,៨៤% (ដប់បួនកន្លក់សញ្ញាប៉ែតសិបបួនភាគរយ) នៃទម្ងន់សរុប។ មេតាំហ្វេតាមីន ឋិតនៅក្នុងតារាងទី២ មាត្រា៥ តាមចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលំអិតក្នុងតារាងឧបសម្ព័ន ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ដោយទម្ងន់សរុបនៃគ្រឿងញៀនទម្ងន់១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីកណ្តក់សញ្ញាបួនក្រាម) ក្នុងនោះមានកម្រិតភាពសុទ្ធស្មើនឹង១៤,៨៤% (ដប់បួនកន្ទក់សញ្ញាប៉ែតសិបបួនភាគរយ) យើងបាន៖

$$\text{កម្រិតភាពសុទ្ធសរុប} = \frac{១៨៣៨,៤ \times ១៤,៨៤}{១០០} = ២៧២,២២៤G$$

(ពីររយចិតសិបពីរកណ្តក់សញ្ញាពីររយម្ភៃបួនក្រាម)

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការសន្និដ្ឋានថា៖ ផ្អែកតាមការពិភាក្សាដេញដោលឃើញថា កម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន ចុះបង្ក្រាបការជួញដូរគ្រឿងញៀននៅសណ្ឋាគារបូលីណាផាឡាស ដោយអនុវត្តតាមវិធានញុះញ៉ង់ ដោយឃាត់ខ្លួនឈ្មោះ [redacted] ផង, [redacted] សុត និងគ្រឿងញៀន រួចបន្តទៅឃាត់ខ្លួនឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ទៀត ។ ជនជាប់ចោទបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាល ប៉ុន្តែនាពេលសវនាការស្រាប់តែបដិសេធថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទៅវិញ។ ការឆ្លើយបដិសេធនេះគ្មានភស្តុតាងស៊ីសង្វាក់ គ្មានតម្លៃជាភស្តុតាង ដែលអាចជឿបាននោះទេ ម្យ៉ាងទៀតមានភស្តុតាងយ៉ាងច្បាស់បញ្ជាក់ថា ក្រុមជនជាប់ចោទបានសហការគ្នាយ៉ាងស្អិតរមួតក្នុងការប្រព្រឹត្តការជួញដូរគ្រឿងញៀន រហូតដល់មានការបង្ក្រាបជាក់ស្តែង។ ដោយផ្អែកតាមលទ្ធផលកោសល្យវិច័យរបស់ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន បញ្ជាក់យ៉ាងច្បាស់ថា វត្ថុចាប់យក ជាសារធាតុញៀន ដែលច្បាប់បានហាមឃាត់ ដូច្នេះស្នើសុំតម្កល់បទចោទដូចដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ជាហេតុតុលាការពិចារណា និងសម្រេច។

-ផ្អែកតាមភស្តុតាងទាំងអស់ខាងលើនេះមានភាពស៊ីសង្វាក់ មានតម្លៃគ្រប់គ្រាន់ អាចជឿបាន ដូច្នេះតុលាការគប្បីពិនិត្យ និងសម្រេច ។

-ចំពោះចម្លើយបដិសេធរបស់ក្រុមជនជាប់ចោទ ដែលបានឆ្លើយបដិសេធនាពេលសវនាការ គឺផ្ទុយគ្នាទាំងស្រុងទៅនឹងចម្លើយដែលពួកគេបានឆ្លើយនៅដំណាក់កាលនីតិវិធីមុន ហើយក៏គ្មានភស្តុតាងស៊ីសង្វាក់ដើម្បីបញ្ជាក់ដែរ ផ្ទុយទៅវិញការព្យាយាមឆ្លើយផ្ទុយពីការពិត ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវរបស់ជនជាប់ចោទម្នាក់ៗនាពេលសវនការនេះឃើញថា គ្មានភាពស៊ីសង្វាក់គ្នានោះទេ ដូច្នេះការឆ្លើយបដិសេធនេះគ្មានតម្លៃជាភស្តុតាងសម្រាប់ឱ្យតុលាការពិចារណាបានឡើយ។

-សេចក្តីសន្និដ្ឋានរបស់លោក [redacted] វិសាល ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ ថា កូនក្តីខ្លួនបានឆ្លើយបដិសេធគ្រប់ដំណាក់កាលថា ខ្លួនពុំមានគ្រឿងញៀនទេ ជាក់ស្តែងសមត្ថកិច្ចក៏មិនមែនចាប់គ្រឿងញៀនពីកូនក្តីខ្លួនដែរ ថ្នាំញៀនគឺស្ថិតនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ផង, [redacted] ស៊ុត អ្នកទាំងពីរនេះ កូនក្តីខ្លួនមិនស្គាល់ទេ។ ចំពោះការដែលកូនក្តីខ្លួនមកភ្នំពេញ កូនក្តីខ្លួនបានធ្វើលិខិតអនុញ្ញាតត្រឹមត្រូវ ហើយមានគោលបំណងច្បាស់លាស់ ដើម្បីទិញគ្រឿងអគ្គីសនី , ទិញថ្នាំពេទ្យ និងមកកំសាន្តនៅភ្នំពេញ មិនមែនមកដើម្បីជួញដូរគ្រឿងញៀន ដូចការចោទប្រកាន់នោះទេ ព្រោះឈ្មោះ ផល្លី, ឈ្មោះ សម្រស់ ទើបជាមេឃ្លោងពិតប្រាកដ។ ការចោទប្រកាន់កូនក្តីខ្លួន នៅពុំមានមានអង្គហេតុច្បាស់លាស់ ពោលគឺមានវិមតិសង្ស័យនៅឡើយ យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យ ត្រូវមានប្រយោជន៍ដល់ជនជាប់ចោទដូច្នេះស្នើសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទ។ ចំណែកលោក [redacted] រិទ្ធី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ ថា អង្គហេតុបានបញ្ជាក់យ៉ាងច្បាស់ថា នៅពុំទាន់មានអំពើ ជួញដូរគ្រឿងញៀនបាន



Scanned with CamScanner

កើតឡើងនៅឡើយ ពោលគឺគ្រឿងញៀនត្រូវបានយកមកទុកលើគ្រែបន្ទប់របស់ឈ្មោះ [redacted] ផង ដែលជាគ្រឿងញៀនរបស់ឈ្មោះ សម្រស់ គឺពុំទាន់មានការដោះដូររវាងអ្នកទិញ និងអ្នកលក់នៅឡើយ ពោលគឺធាតុសត្យានុម័តមិនទាន់ស្តែងឡើងនៅឡើយ ដូច្នេះមិនអាចអនុវត្តតាមមាត្រា៤០ ផ្តន្ទាទោសលើជនជាប់ចោទបានឡើយ។ មាត្រា៣៥៧ បញ្ញាក់ថាអង្គហេតុដែលសរសេរនៅក្នុងសាលក្រមត្រូវតែច្បាស់លាស់ ប៉ុន្តែអង្គហេតុខាងលើនេះនៅមានវិមតិសង្ស័យនៅឡើយ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទ និងស្នើសុំឱ្យតុលាការសម្រេចប្រគល់រថយន្តឱ្យម្ចាស់ដើមវិញ។ វីឯសេចក្តីសន្និដ្ឋានរបស់លោក [redacted] ហៃ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត ថាកូនក្តីខ្លួនពុំមានតួនាទីជាអ្នកដឹកជញ្ជូនរឿងញៀនទេ ដោយហេតុសារកូនក្តីខ្លួនពុំបានដឹងជាមុនថា នៅក្នុងការបូបមានគ្រឿងញៀន ហើយការបូបនោះជារបស់ឈ្មោះ សម្រស់ មិនមែនជារបស់កូនក្តីខ្លួនទេ កូនក្តីខ្លួនមិនមែនជាកាន់យួការបូបនោះឡើយ ថ្នាំញៀននោះគឺនៅលើគ្រែ។ កូនក្តីខ្លួនមកភ្នំពេញជាមួយឈ្មោះ សម្រស់ ព្រោះឈ្មោះ សម្រស់ប្រាប់ថា ឱ្យខ្លួនមកធ្វើការជាជាងសំណង់ សាងសង់ផ្ទះបងថ្លៃរបសគេ ដោយសន្យាឱ្យអង្គពីរបេ អង្គហេតុខាងលើនេះ មិនមានធាតុផ្សំគ្រប់គ្រាន់ពីបទ ជួញដូរគ្រឿងញៀននោះទេ ម្យ៉ាងវិញទៀតកូនក្តីខ្លួនពុំសូវមានការយល់ដឹង ដូច្នេះស្នើសុំឱ្យតុលាការសម្រេចឱ្យរួចផុតពីបទចោទ។ ជាសេចក្តីសន្និដ្ឋានមិនមានភស្តុតាងបញ្ជាក់ស៊ីសង្វាក់មិនអាចឱ្យតុលាការទទួលយកមកពិចារណា និងសម្រេចបានទេ ដោយហេតុថា ការប្រតិបត្តិការជួញដូរគ្រឿងញៀននេះ គឺកើតឡើងតាមរយៈវិធានញុះញ៉ង់ គឺក្រុមជនជាប់ចោទទាំងអស់បានចូលរួមរៀបផែនការដើម្បីដោះដូរគ្រឿងញៀន តាមរយៈសំណើទិញរបស់កម្លាំងសម្ងាត់ ដែលដំបូងឡើយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ កម្លាំងសម្ងាត់បានណាត់ជួបជាមួយក្រុមជនជាប់ចោទ ដើម្បីពិភាក្សារឿងជួញដូរគ្រឿងញៀន និងបង្ហាញប្រាក់ បន្ទាប់មកនៅថ្ងៃទី២៣ ក្រុមជនជាប់ចោទ និងកម្លាំងសម្ងាត់បានណាត់គ្នាប្រគល់ទំនិញ ដូច្នេះសបញ្ជាក់ឱ្យឃើញថាចេតនា និងសកម្មភាពនៃការជួញដូរគ្រឿងញៀនបានកើតឡើងរួចទៅហើយ គឺការជួញដូរគ្រឿងញៀនបានប្រព្រឹត្តឡើងតាមដំណាក់កាលដូចជាការណាត់ជួប ការដឹកជញ្ជូន និងការណាត់ប្រគល់ទំនិញ គ្រាន់តែមិនទាន់បានបញ្ចប់ ត្រូវបានសមត្ថកិច្ចបានបង្ក្រាបតែម្តង។ អង្គហេតុនៃការជួញដូរគ្រឿងញៀន បានកើតឡើងយ៉ាងច្បាស់លាស់ ហើយក៏គ្មានវិមតិសង្ស័យដែរ ស៊ីសង្វាក់ទៅនឹងមមាត្រា៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សំដីចុងក្រោយរបស់ជនជាប់ចោទ បានស្នើសុំឱ្យតុលាការជួយរកយុត្តិធម៌ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ តែការស្នើសុំឱ្យដោះលែងពួកខ្លួនមិនត្រឹមត្រូវតាមច្បាប់ តុលាការមិនអាចធ្វើការពិចារណា និងសម្រេចបានទេ។

-ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត មិនទទួលបានការអប់រំល្អ មិនចេះអក្សរ គ្មានការយល់ដឹងខ្ពស់ ដែលពួកគាត់ទាំងពីរមានដើមកំណើតនៅខេត្តព្រះវិហា មានឪពុកម្តាយជាជនជាតិភាគតិច ហើយមានជីវភាពក្រីក្រ ហើយមិនមែនជាម្ចាស់ថ្នាំញៀនផ្ទាល់នោះទេ ដោយផ្អែកតាមកាលៈទេសៈ និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទតម្រូវ តុលាការគម្បីអនុវត្តប្បញ្ញត្តិស្តីពីស្ថានសម្រាលទោសជូនជនជាប់ចោទទាំងពីររូបស្មើនឹងកម្រិតអប្បបរមានៃទោសដែលច្បាប់បានកំណត់។ រីឯជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភន់ ពួកគេជាអ្នកផ្តើមគំនិត និងជាម្ចាស់ថ្នាំញៀន គេបានលួកដៃប្រព្រឹត្តយ៉ាងសកម្មហេតុនេះតុលាការ គប្បីពិចារណា និងសម្រេចផ្តន្ទាទោសខ្ពស់ជាងអ្នកទាំងពីរខាងលើ ដើម្បីឱ្យសមស្របអំពើប្រព្រឹត្តរបស់ខ្លួនតាមច្បាប់។

-អំពីវត្ថុចាប់តាមវត្ថុចាប់តាមកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរលេខ៧៧០វគ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញរួមមាន៖

- ប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យថា គ្រឿងញៀនទម្ងន់១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) គប្បីសម្រេចរឹបអូសបំផ្លាញចោលតាមមាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

- ថយន្តមួយគ្រឿងម៉ាកTOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, គប្បីសម្រេចរឹបអូស តាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។
- ទូរស័ព្ទដៃម៉ាក wellcom-S101 មួយគ្រឿង , ទូរស័ព្ទដៃម៉ាកNOKIA ចំនួនមួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង ,លិខិតឆ្លងដែនចំនួនពីរក្បាល, កូនសៀវភៅចំនួនពីរក្បាល, កាតមានអក្សរឡាវមានលេខ៨៨៨៨៨៨៣០០០២៤ ចំនួនមួយសន្លឹក, កាតមានអក្សរឡាវលេខA1-0040165 និងស៊ីមកាតចំនួនប្រាំ គប្បីសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## **ទិនិច្ឆ័យសេចក្ដី**

I- ផ្ដន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក- ឈ្មោះ [redacted] **គុបភន់** ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ

ខ- ឈ្មោះ [redacted] **ខាំបៃ** ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន**២៥ (ម្ភៃប្រាំ) ឆ្នាំ** គិតចាប់ពីថ្ងៃចាប់ខ្លួន (**២៣-១២-២០១២**) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន **៥០.០០០.០០០៛** (ហាសិបលាន) **រៀល** ដាក់ចូលថវិការដ្ឋ។

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារបូលីណាផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

គ- ឈ្មោះ [redacted] **ថង** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ

**ឃ**- ឈ្មោះ [redacted] **ស៊ីត** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន**២០ (ម្ភៃ) ឆ្នាំ** គិតចាប់ពីថ្ងៃចាប់ខ្លួន (**២៣-១២-២០១២**) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន **៤០.០០០.០០០៛** (**សែសិបលាន**) រៀល ដាក់ចូលថវិការដ្ឋ។

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៥០៣ សណ្ឋាគារបូលីណាផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

II- បណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទណ្ឌិតឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ អនុវត្តទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ចប់សព្វគ្រប់ជាស្ថាពរ តាមអំណាចសាលក្រមនេះរួច តាមមាត្រា៦១ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

III- វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរលេខ៧៧០វក ចុះថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក-ប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យថា គ្រឿងញៀនទម្ងន់១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) គប្បីសម្រេចរឹបអូសបំផ្លាញចោលតាមមាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, រឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

គ-ទូរស័ព្ទដៃម៉ាក wellcom-S101 មួយគ្រឿង , ទូរស័ព្ទដៃម៉ាកNOKIA ចំនួនមួយគ្រឿង ,ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង ,លិខិតឆ្លងដែនចំនួនពីរក្បាល, កូនសៀវភៅចំនួនពីរក្បាល, កាតមានអក្សរឡាវមានលេខ៨៨៨៨៨៣០០០២៤ ចំនួនមួយសន្លឹក, កាតមានអក្សរឡាវលេខA1-0040165 និងស៊ីមកាតចំនួនប្រាំ ប្រគល់ឲ្យម្ចាស់ដើមនៃទ្រព្យវិញតាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទទាំងបួន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner